**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន
និង សង្គ្រោះជនពិការដោយសារមីន

លេខ : ៥៥៨.../..អន../..អចម../..២០២៥

# សេចក្តីណែនាំ
# ស្តីពី
# វិធានការបន្ទាន់ក្នុងការអប់រំផ្សព្វផ្សាយ ការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

អំឡុងពេលនៃសកម្មភាពវាយប្រហាររបស់យោធាថៃមកលើកម្ពុជា ដែលបានចាប់ផ្តើមលើកទី១ ពីថ្ងៃទី ២៤ ដល់ ២៨ ខែកក្កដា ឆ្នាំ២០២៥ និងលើកទី២ ពីថ្ងៃទី៧ ដល់ ២៧ ខែធ្នូ ឆ្នាំ២០២៥ យោធាថៃបានប្រើប្រាស់យុទ្ធោបករណ៍ធុនធ្ងន់គ្រប់ប្រភេទមកលើតំបន់ស៊ីវិល ដែលបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈ មណ្ឌលសុខភាព សាលារៀន វត្តអារាម ប្រាសាទបុរាណ និងបង្ខំឱ្យប្រជាជនរាប់ម៉ឺនគ្រួសារត្រូវជម្លៀសចេញពីលំនៅដ្ឋានទៅកាន់ទីតាំងសុវត្ថិភាព។ ទោះបីសកម្មភាពវាយប្រហារបានបញ្ចប់ទៅហើយក្តី ប៉ុន្តែសព្វាវុធដែលបានប្រើប្រាស់ដូចជា គ្រាប់បែកចង្កោម គ្រាប់ផ្លោង គ្រាប់ទម្លាក់ ផ្សែងពុល និងយុទ្ធភណ្ឌផ្សេងទៀត មានមួយចំនួននៅមិនទាន់ផ្ទុះដែលអាចបណ្តាលឱ្យផ្ទុះនិងបង្កគ្រោះថ្នាក់គ្រប់ពេលវេលា។

ដើម្បីបង្ការនិងទប់ស្កាត់គ្រោះថ្នាក់ដែលអាចកើតមានជាយថាហេតុ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន(អាជ្ញាធរមីន) សូមធ្វើការណែនាំដល់ភាគីពាក់ព័ន្ធទាំងអស់ឱ្យអនុវត្តនូវវិធានការដូចខាងក្រោម៖

**១- ប្រតិបត្តិករអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ**

- ចូលរួមជម្រុញ លើកទិសដៅ និងអនុវត្តការងារអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះដល់ប្រជាជននៅតាមមណ្ឌលសុវត្ថិភាព និងតាមខ្នងផ្ទះ
- បង្កើនក្រុមចុះអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ ឱ្យអស់លទ្ធភាពតាមដែលអាចធ្វើទៅបាន
- រៀបចំផលិតសម្ភារៈសំខាន់ៗដែលបម្រើដល់ការងារអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ចូលរួមជាមួយក្រុមការងារផែនការសកម្មភាពមីនខេត្ត(ម៉ាពូ) ក្នុងការរិះរកគំនិតថ្មីៗដែលជាប្រយោជន៍ដល់ការអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ

- សហការជាមួយអាជ្ញាធរមូលដ្ឋាន ដោយបញ្ជាក់ពីគោលបំណងជាក់លាក់មុនចុះបំពេញការងារអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

២- គណៈកម្មាធិការសកម្មភាពមីនខេត្ត និងក្រុមការងារផែនការសកម្មភាពមីនខេត្ត (ភីម៉ាក់/ម៉ាពូ)

- ផ្តល់កិច្ចសហការ និងសម្របសម្រួល ដើម្បីធានាឱ្យប្រតិបត្តិករអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ អាចចុះទៅបំពេញការងារបាននៅតាមមណ្ឌលសុវត្ថិភាព និងតាមខ្នងផ្ទះ
- ពិនិត្យលទ្ធភាពបញ្ច្រាបការងារអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ រាល់ពេលអង្គភាព ក្រសួង ស្ថាប័ននានាចុះទៅបំពេញការងារនៅមណ្ឌលសុវត្ថិភាព និងខ្នងផ្ទះ
- តាមដាន និងរាយការណ៍ជាប្រចាំមកអាជ្ញាធរមីន អំពីវឌ្ឍនភាពនៃការអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារគ្រឿងផ្ទុះ។

៣- ដៃគូអភិវឌ្ឍន៍ និងភាគីពាក់ព័ន្ធ

- ផ្តល់ការលើកទឹកចិត្តដោយគាំទ្រ សកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះនៅតាមមណ្ឌលសុវត្ថិភាព និងតាមខ្នងផ្ទះ
- ស្វែងរកជំនួយគាំទ្រ ដល់សកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ។

៤- អគ្គលេខាធិការដ្ឋានអាជ្ញាធរមីន

- ដឹកនាំ និងសម្របសម្រួល ដើម្បីធានាឱ្យមានការចុះទៅអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ នៅតាមទីតាំងសុវត្ថិភាពដែលពលរដ្ឋភៀសសឹកស្នាក់នៅ
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័ន ប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ដើម្បីទទួលបានការគាំទ្រឱ្យមានសកម្មភាពអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- រៀបចំឱ្យក្រុមត្រួតពិនិត្យអាជ្ញាធរមីន ចុះត្រួតពិនិត្យការងារអប់រំផ្សព្វផ្សាយការយល់ដឹងពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះដែលបំពេញដោយប្រតិបត្តិករ
- សម្របសម្រួលជាមួយប្រតិបត្តិករ ឱ្យមានកិច្ចសហប្រតិបត្តិការចុះអប់រំផ្សព្វផ្សាយការយល់ដឹងដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីស្នើសុំបន្តការគាំទ្រ និងការចូលរួមអប់រំផ្សព្វផ្សាយការយល់ដឹងដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ
- ដឹកនាំ ចាត់ចែង និងសម្របសម្រួលការងារពាក់ព័ន្ធបន្ទាន់ផ្សេងៗ តាមស្ថានភាពជាក់ស្តែង។

ទទួលបានសេចក្តីណែនាំនេះ អគ្គលេខាធិការដ្ឋានអាជ្ញាធរមីន គណៈកម្មាធិការសកម្មភាពមីនរាជធានី-ខេត្ត(ភីម៉ាក់) ក្រុមការងារផែនការសកម្មភាពមីនរាជធានី-ខេត្ត(ម៉ាពូ) ប្រតិបត្តិករអប់រំផ្សព្វផ្សាយការយល់ដឹង

ពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះជាតិ-អន្តរជាតិ និងភាគីពាក់ព័ន្ធទាំងអស់ ត្រូវផ្តល់កិច្ចសហការ និងចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១២កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២៥

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**អនុប្រធានទី១**

**លី ធុជ**

<u>**ចម្លងជូន៖**</u>

- គណៈកម្មាធិការសកម្មភាពមីនខេត្ត(ភីម៉ាក់)
- ក្រុមការងារផែនការសកម្មភាពមីនខេត្ត(ម៉ាពូ)
- គ្រប់ប្រតិបត្តិករសកម្មភាពមីន
- ដៃគូអភិវឌ្ឍ និងភាគីដែលពាក់ព័ន្ធ
  «ដើម្បីអនុវត្ត»
- ឯកសារ កាលប្បវត្តិ